00747733

E131

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 10 / 2011
ម៉ោង (Time/Heure) : 16:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យូរ ឧត្តរា |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

---

# ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានបឋមទោសប្រកាន់ និងសវនាការលើអង្គសេចក្តី នៃសំណុំរឿង ០០២

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGÈS

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1]។

**បន្ទាប់ពី** អង្គជំនុំជម្រះសាលាដំបូងបានធ្វើសវនាការបឋមលើសំណុំរឿង ០០២ កាលពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ រួចមក។

**ហេតុដូច្នេះ** អង្គជំនុំជម្រះកំណត់យកថ្ងៃ ច័ន្ទ ទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជាថ្ងៃនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់សម្រាប់សំណុំរឿង ០០២។

**បន្ថែមពីលើនេះ** អង្គជំនុំជម្រះកំណត់យកថ្ងៃ ច័ន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ រហូតដល់ថ្ងៃ សុក្រ ទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ ជាថ្ងៃធ្វើធ្វើសវនាការដំបូងលើការពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២។

**ផ្តល់ជូន** ព័ត៌មានបន្ថែមដូចខាងក្រោមទៅភាគី និងសាធារណជនពាក់ព័ន្ធនឹងបែបបទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២៖

## ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី

សេចក្តីសន្និដ្ឋានចោទប្រកាន់សម្រាប់សំណុំរឿង ០០២ នឹងចាប់ផ្តើមធ្វើនៅក្នុងបន្ទប់សវនាការធំរបស់ អ.វ.ត.ក នាវេលាម៉ោង ៩ ព្រឹក ថ្ងៃ ច័ន្ទ ទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងនៅថ្ងៃបន្ទាប់។ សេចក្តីសន្និដ្ឋាននេះនឹងត្រូវធ្វើជាសាធារណៈ។

សវនាការនឹងចាប់ផ្តើមដោយការអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទម្នាក់ៗ អនុលោមតាមវិធាន *៨៩ស្ទួន* (១) នៃវិធានផ្ទៃក្នុង។ ដោយហេតុថាជនជាប់ចោទ និងភាគីបានទទួលការជូនដំណឹងរួចហើយអំពី

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

ការវិភាគអង្គហេតុពេញលេញនៅក្នុងដីកាដំណោះស្រាយ ហេតុដូច្នេះ ពុំមានការអានការវិភាគអង្គហេតុនៅក្នុងសវនាការនេះឡើយ។

ជាកិច្ចបន្ទាប់ អង្គជំនុំជម្រះសាលាដំបូងនឹងទុកឱកាសឲ្យសហព្រះរាជអាជ្ញាធ្វើសន្និដ្ឋានចោទប្រកាន់ អនុលោមតាមវិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាមានរយៈពេលចំនួន ២ ថ្ងៃសម្រាប់ការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់។ ដូចមានពន្យល់នៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ (ឯកសារ E124/7) ជនជាប់ចោទត្រូវប្រឈមនឹងការចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២។ ថ្វីត្បិតដីកាសម្រេចបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ (ឯកសារ E124) បានបំបែកការជំនុំជម្រះជាដំណាក់កាលក្ដី ក៏អង្គជំនុំជម្រះរំពឹងថាសវនាការដំណាក់កាលដំបូងនេះនឹងផ្ដល់ជាមូលដ្ឋានរួមមួយសម្រាប់បទចោទទាំងអស់ រួមទាំងបទចោទនានាដែលអង្គជំនុំជម្រះនឹងលើកយកទៅពិនិត្យក្នុងសវនាការដំណាក់កាលបន្ទាប់។ អាស្រ័យហេតុនេះ សហព្រះរាជ-អាជ្ញាត្រូវធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ពាក់ព័ន្ធនឹងរាល់គ្រប់បទចោទ និងការចោទប្រកាន់លើអង្គហេតុទាំងអស់ប្រឆាំងនឹងជនជាប់ចោទដែលមាននៅក្នុងដីកាដំណោះស្រាយ។

អនុលោមតាមវិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុង ជនជាប់ចោទម្នាក់ៗ ឬមេធាវីរបស់ជនជាប់ចោទរូបនោះ នឹងមានឱកាសធ្វើការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះ-សាលាដំបូងទុកពេលវេលាចំនួនកន្លះថ្ងៃសម្រាប់ឲ្យក្រុមមេធាវីការពារក្ដីនីមួយៗធ្វើសេចក្ដីសន្និដ្ឋានតប។ ប្រសិនបើជនជាប់ចោទមានបំណងធ្វើសេចក្ដីសន្និដ្ឋានណាមួយនៅក្នុងអំឡុងពេលសវនាការនេះ ការធ្វើសេចក្ដីសន្និដ្ឋានរបស់ជនជាប់ចោទរូបនោះ គឺជាផ្នែកមួយនៃពេលវេលាកន្លះថ្ងៃដែលអង្គជំនុំជម្រះបានផ្ដល់ឲ្យក្រុមមេធាវីការពារក្ដីនោះ។

អនុលោមតាមវិធាន ៨៩ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហមេធាវីនាំមុខ ឬចម្លើយតបណាមួយទៅនឹងសេចក្ដីសន្និដ្ឋានរបស់ភាគីផ្សេងៗនឹងពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើ ឬលើកយកមកពិនិត្យពិចារណាឡើយ។ ដោយអនុលោមតាមការអនុវត្តកន្លងមក ពុំមានការដាក់កំហិតណាមួយលើការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានចំនួនកំណត់នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់នេះឡើយ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងជាអ្នកកំណត់នូវចំនួនមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវអង្គុយនៅកន្លែងដែលបម្រុងទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងបន្ទប់សវនាការ។

បន្ទាប់ពីចប់សវនាការពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ អង្គជំនុំជម្រះនឹងធ្វើសវនាការដើម្បីពិនិត្យភស្តុតាងលើសំណុំរឿង 00២ ដែលនឹងចាប់ផ្តើមនៅម៉ោង ៩ ព្រឹក ថ្ងៃ ច័ន្ទ ទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២0១១ ដោយអនុលោមតាមបញ្ជីឈ្មោះសាក្សីដែលអង្គជំនុំជម្រះនឹងផ្ញើជូនទៅភាគី។ អនុលោមតាមវិធាន ៧៩(៦) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបញ្ជាក់ថាសវនាការលើអង្គសេចក្តីនេះនឹងធ្វើជាសាធារណៈឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

អង្គជំនុំជម្រះនឹងបញ្ចប់សវនាការនេះមិនឲ្យហួសពីថ្ងៃ សុក្រ ទី ១៦ ខែ ធ្នូ ឆ្នាំ ២0១១ ឡើយ។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងឈប់សម្រាកបុណ្យណូអែល និងបុណ្យចូលឆ្នាំសកលរហូតដល់ថ្ងៃ ពុធ ទី 0៤ ខែ មករា ឆ្នាំ ២0១២។ នៅចន្លោះថ្ងៃឈប់សម្រាកនេះ ផ្នែកគ្រប់គ្រងតុលាការនឹងពុំទទួលយកឯកសារណាមួយដែលភាគីដាក់ឡើយ។ ប៉ុន្តែពេលវេលាកំណត់សម្រាប់ការដាក់ឯកសារក៏នឹងត្រូវគិតក្នុងអំឡុងពេលតុលាការឈប់សម្រាកនេះផងដែរ។ ប្រសិនបើពេលវេលាកំណត់ត្រូវចំនឹងថ្ងៃណាមួយក្នុងចំណោមថ្ងៃឈប់សម្រាកខាងលើ កាលបរិច្ឆេទសម្រាប់ភាគីដាក់ឯកសារនឹងផុតកំណត់នៅថ្ងៃ ព្រហស្បតិ៍ ទី 0៥ ខែ មករា ឆ្នាំ ២0១២។

អង្គជំនុំជម្រះសាលាដំបូងនឹងបន្តធ្វើសវនាការនៅថ្ងៃ ច័ន្ទ ទី 0៩ ខែ មករា ឆ្នាំ ២0១២។

អង្គជំនុំជម្រះនឹងផ្តល់ជូនព័ត៌មានបន្ថែមពាក់ព័ន្ធនឹងកាលបរិច្ឆេទសម្រាប់ផ្នែកបន្តបន្ទាប់នៃសវនាការ ព្រមទាំងថ្ងៃឈប់សម្រាករបស់តុលាការនៅក្នុងពេលសមស្របខាងមុខ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២0១១
ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C
ECCC

និល ណុន